ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី១១ លេខ ៤ | តុលា - ធ្នូ ឆ្នាំ២០០៧ | តម្លៃ ១.៥០០៛

# ប្រទេសកម្ពុជាៈ កំណើនសេដ្ឋកិច្ច និងលទ្ធផលតាមវិស័យក្នុងឆ្នាំ ២០០៦

**ភីម រ៉ុនស៊ីណារិទ្ធិ ពិភាក្សាលើការវាយតំលៃក្នុងគណនីជាតិឆ្នាំ២០០៦ ដោយវិទ្យាស្ថានជាតិស្ថិតិ បកស្រាយលើតួលេខសំខាន់ៗនៃការវាយតំលៃនេះ និងផ្តល់មតិលើបញ្ហាមួយចំនួនដែលផុសឡើង ។***

អត្ថបទនេះ ធ្វើការពិភាក្សាពីការវាយតំលៃក្នុងគណនីជាតិ កសាងដោយ វិទ្យាស្ថានជាតិស្ថិតិ (NIS) សំរាប់ឆ្នាំ២០០៦ ដែលផ្សាយចេញនៅខែឧសភា ឆ្នាំ២០០៧ ។ អត្ថបទ មានបកស្រាយពីតួលេខសំខាន់ៗនៃការវាយតំលៃនេះ និងផ្តល់មតិលើបញ្ហាមួយចំនួនដែលផុសឡើង ដូចជា ចំណងតភ្ជាប់អនុវិស័យសំខាន់ៗ ទៅនឹងផ្នែកដទៃទៀតនៃសេដ្ឋកិច្ច និងការកែសំរួលកំពុងអនុវត្តលើគណនីជាតិ ។



*កសិករកំពុងបាចជីក្នុងស្រែនៅខេត្តតាកែវ ឆ្នាំ២០០៦*

## កំណើន ផសស ពិតសរុប

សេដ្ឋកិច្ចប្រទេសកម្ពុជាបន្តមានដំនើរការយ៉ាងល្អក្នុងឆ្នាំ២០០៦ ។ ផសស ពិត កើនឡើង ១០,៦% (២០០៦) ដូច្នេះគឺវាមានកំនើនជាលេខពីរខ្ទង់ បានបីឆ្នាំជាប់ៗគ្នាហើយ ។ ប៉ុន្តែបើធៀបទៅនឹងឆ្នាំ២០០៥ (១៣,៦%) វាថយចុះកំណើនដោយសារវិស័យកសិកម្មបានរីកលូតលាស់យឺតជាងមុន ដូចមានបង្ហាញក្នុងក្រាហ្វិក១ និងតារាង១។ នៅឆ្នាំ២០០៦ ផសស គិតក្នុងមនុស្សម្នាក់ កើនដល់ ១,៧១៨ លានរៀល (៤១៩ ដុល្លារ) រឺកើន ៨,២% ធៀបនឹងឆ្នាំ ២០០៥ ។ សន្ទុះកំនើនភាគច្រើនបានមកពីវិស័យឧស្សាហកម្មដែលមានកំនើនយ៉ាងច្រើនក្នុងផ្នែកកាត់ដេរ សាងសង់ និងពីវិស័យសេវាកម្មផងដែរដែលមានកំនើនគួរកត់សំគាល់ ក្នុងផ្នែកទេសចរណ៍ អចលនទ្រព្យ សេវាកម្មជំនួញ និងសេវាកម្មផ្សេងៗទៀត ។ ស្របតាមលំនាំធម្មតា គេតែងពិនិត្យឃើញជាញឹកញាប់នៅប្រទេសកម្ពុជាដែលមានឆ្នាំខ្លះល្អ ឆ្នាំខ្លះមិនល្អ វិស័យកសិកម្មបានធ្លាក់កំណើនគួរកត់សំគាល់

*ក្រាហ្វិក១: កំណើន ផសស (១៩៩៤-២០០៦)*




* ភីម រ៉ុនស៊ីណារិទ្ធិ អ្នកស្រាវជ្រាវនៅ វបសអ ។ អត្ថបទនេះ ផ្អែកលើឯកសារវាយតំលៃ គណនីជាតិឆ្នាំ២០០៦ ដោយវិទ្យាស្ថានជាតិស្ថិតិ ដែលចេញផ្សាយនៅខែឧសភា ២០០៧ ។

## មាតិកា

ប្រទេសកម្ពុជាៈ កំណើនសេដ្ឋកិច្ច និងលទ្ធផលតាមវិស័យក្នុងឆ្នាំ២០០៦ ....... ១
តើគ្រួសារស្ត្រីមេគ្រួនៅជនបទទាំងអស់សុទ្ធតែក្រីយ៉ាងណា ? ........................ ៥
ការស្វែងយល់ពីតួនាទីមូលធនសង្គម នៅពេលមានទឹកជំនន់និងគ្រោះរាំងស្ងួត ........................................ ៩
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........................................ ១៣
— ស្ថានភាពក្នុងប្រទេស ........................................ ១៥
— សន្ទស្សន៍សេដ្ឋកិច្ច ........................................ ១៨
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI ........................................ ២០

*តារាង ១. ផសស ពិត និង កំនើនតាមផ្នែក*

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 |
|---|---|---|---|---|---|---|---|
| ផសស ពិត (ពាន់លានរៀល) | 14,083 | 15,215 | 16,210 | 17,589 | 19,351 | 21,956 | 24,334 |
| ផសស ពិត ក្នុងមនុស្សម្នាក់ (ពាន់រៀល) | 1111 | 1180 | 1237 | 1320 | 1428 | 1588 | 1718 |
| កំនើនពិត ធៀបនឹងឆ្នាំមុន (%) | | | | | | | |
| កសិកម្ម | -0.4 | 3.6 | -2.5 | 10.5 | -0.9 | 15.7 | 5.5 |
| ឧស្សាហកម្ម | 31.2 | 11.2 | 17.1 | 12 | 16.6 | 12.7 | 18.3 |
| សេវាកម្ម | 8.9 | 10.8 | 7.6 | 5.9 | 13.3 | 12.7 | 10.3 |
| ពន្ធលើផលិតផល ដកឧបត្ថម្ភធន | 4.5 | 2.5 | 12.6 | 0.6 | 21.2 | 11.7 | 7.6 |
| ផសស | 8.8 | 8 | 6.5 | 8.5 | 10 | 13.5 | 10.8 |
| ផសសក្នុងមនុស្សម្នាក់ | 7 | 6.3 | 4.8 | 6.7 | 8.2 | 11.2 | 8.2 |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិ ២០០៧*

នៅឆ្នាំ២០០៦ បើធៀបនឹងឆ្នាំ២០០៥ ។ ប៉ុន្តែវិស័យនេះ នៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងជីវភាពរស់នៅតាមទីជនបទ ដោយប្រជាជនភាគច្រើននៅតែពឹងផ្អែកលើដំណាំស្រូវ ដើម្បីទ្រទ្រង់ជីវិត ។

## កសិកម្ម

វិស័យកសិកម្មនៅកម្ពុជារួមចំនែក ២៨% នៃ ផសស រឺ ១,៦% នៅក្នុងកំនើន ផសស សរុប (១០,៦%) និងផ្តល់ការងារអោយ ៥៧,៤% នៃកំលាំងពលកម្មសរុប នៅឆ្នាំ២០០៦ (តារាង២) ។ កសិកម្មរួមបញ្ចូល ៤ អនុវិស័យគឺ ការដាំដុះ ការចិញ្ចឹមសត្វ ជលផល និងព្រៃឈើ ។ នៅឆ្នាំ២០០៦ តំលៃបន្ថែមដុលពិតនៃវិស័យនេះ កើន ៥,៥% ធៀបនឹងកំនើន ១៥,៧% នៅឆ្នាំ២០០៥ ដោយសារផលដំណាំ (សមាសភាគសំខាន់នៃវិស័យនេះ) បានរីកលូតលាស់ យឺតជាងឆ្នាំមុន ពីព្រោះមានទឹកជំនន់ ការរាំងស្ងួត[1] ជំងឺ រីសត្វល្អិតបំផ្លាញដំណាំ នៅតាមបណ្តាខេត្តមួយចំនួន ។ ជាទូទៅ អត្រាកំនើនអនុវិស័យដាំដុះ ប្រែប្រួលជាខ្លាំង (ឡើងដល់កំពូល និងធ្លាក់ដល់បាត) ដែលឆ្លុះបញ្ចាំងពីការពឹងផ្អែកយ៉ាងខ្លាំងលើទឹកភ្លៀង និងការងាយរងគ្រោះដោយកត្តាធាតុអាកាសមិនអំណោយផល ។

*តារាង ២. លទ្ធផលនៃវិស័យកសិកម្ម (ឆ្នាំ២០០៥-២០០៦) គិតជា %*

| | អត្រាកំនើនពិត | | ចំណែកក្នុង ផសស | | ការចូលរួមក្នុងកំនើន ផសស | |
|---|---|---|---|---|---|---|
| | 2005 | 2006 | 2005 | 2006 | 2005 | 2006 |
| កសិកម្ម | **15.7** | **5.5** | **29.5** | **28.1** | **4.5** | **1.6** |
| ដំណាំ | 27.6 | 5.3 | 15 | 14.3 | 3.7 | 0.8 |
| សត្វចិញ្ចឹម រួមទាំង បក្សី | 5.6 | 8.2 | 4.5 | 4.4 | 0.3 | 0.4 |
| ជលផល | 5.6 | 3.8 | 7.8 | 7.3 | 0.5 | 0.3 |
| ព្រៃឈើ និង ការកាប់ឈើ | 5.1 | 7 | 2.2 | 2.1 | 0.1 | 0.2 |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិ ២០០៧*

ទន្ទឹមគ្នានេះ ការចិញ្ចឹមសត្វ នេសាទ និងព្រៃឈើ បានកើនឡើងគួរអោយកត់សំគាល់ ប៉ុន្តែបូកបញ្ចូលគ្នាមក មានចំនែកក្នុងកំនើន ផសស តិចជាង ១% គឺប្រហែលគ្នានឹងការដាំដុះដែរ ។ ផលិតកម្មសត្វចិញ្ចឹម និងបសុបក្សី បន្តជួបឧបសគ្គនៃជំងឺឆ្លង ។ យោងតាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការផ្ទុះជំងឺផ្តាសាយបក្សី មានដល់ ៦លើក នៅឆ្នាំ២០០៦ ធៀបនឹងពីរលើក ប៉ុណ្ណោះនៅឆ្នាំ២០០៥ ។ វាបានបណ្តាលអោយបសុបក្សី ៧៧៦៧ក្បាលស្លាប់ ហើយ បក្សី ១១១៣ក្បាលទៀត ត្រូវបានបំផ្លាញចោល ។ ក្នុងអនុវិស័យជលផល វារីវប្បកម្មខ្នាតតូច នឹងតាមគ្រួសារ បានកើនឡើងពិសេសក្នុងរយៈពេល ៤ឆ្នាំចុងក្រោយនេះ ។ តំលៃបន្ថែមក្នុងអនុវិស័យព្រៃឈើ អាចប៉ាន់ស្មានទាបពេក ដោយសារមានការកាប់ឈើខុសច្បាប់ និងការកំនត់ទាបពេកនូវតួលេខតំលៃពិតនៃផលិតផលមិនមែនឈើហ៊ុប ។ ឧទាហរណ៍ ប្រជាជនយ៉ាងច្រើនមានជីវភាពក្រីក្រ និងត្រូវពឹងផ្អែកលើព្រៃឈើ ទាំងសំរាប់ធ្វើអុសដុត និងសំរាប់ប្រមូលយកផលិតផលមិនមែនឈើហ៊ុប ដើម្បីបង្កើតចំនូល និងបង្កើនការហូបចុក ។ សំពាធសហគមន៏ សង្គមក្នុងទំរង់ជាការប្រមូលយកអុស កសិកម្មផ្លាស់ទី និងការកែប្រែដីជាអចិន្ត្រៃយ៏ ក៏ជាមូលហេតុសំខាន់នៃបាត់បង់ និងខូចគុណភាព្រៃឈើដែរ ។ ការសិក្សារបស់ វបសអ-CDRI បង្ហាញថា អភិបាលកិច្ចធនធានធម្មជាតិ ជាបញ្ហាសំខាន់[2]បំផុត និងត្រូវគ្រប់គ្រងឱ្យមានចីរភាពដើម្បីកាត់បន្ថយភាពក្រីក្រ ។

## វិស័យឧស្សាហកម្ម

ឧស្សាហកម្មចូលរួមចំនែក ២៩% ក្នុង ផសស និងប្រើប្រាស់ប្រហែល ១៤,៥% នៃកំលាំងពលកម្មសរុបនៅឆ្នាំ២០០៦ ។ វិស័យនេះរួមចំនែក ៤,៩% ដល់ កំនើន ផសស ធៀបនឹង ៣,៤% នៅឆ្នាំ២០០៥ (តារាង៣) ដោយសារជាសំខាន់ កំនើនខ្ពស់ជាងមុននៃផលិតកម្ម ដែលនាំមុខដោយឧស្សាហកម្មកាត់ដេរ និងការបន្តរីកដុះដាលសកម្មភាពសាងសង់ នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប ។

វាយនភ័ណ្ឌ និងផលិតកម្មសំលៀកបំពាក់ ជាកត្តាចំបងជួយទ្រទ្រង់វិស័យឧស្សាហកម្ម ក៏ដូចជាសេដ្ឋកិច្ចទាំងមូល ។ វាបានរីកដុះដាលយ៉ាងលឿន ចាប់ពីចុងទសវត្សរ៏១៩៩០ ដោយសារមានលក្ខខណ្ឌពាណិជ្ជកម្មអំណោយផលល្អនៃកិច្ចព្រមព្រៀងវាយនភ័ណ្ឌចំរុះ (Multi-Fibre Agreement: MFA) ។ បន្ទាប់ពីកិច្ចព្រមព្រៀងបានបញ្ចប់នៅថ្ងៃ១ មករា ២០០៥ អ្នកខ្លះបានទាយទុកថា សេដ្ឋកិច្ចកម្ពុជាអាចត្រូវប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ប៉ុន្តែតួលេខចុងក្រោយ បានបដិសេធការប៉ាន់ស្មានទាំងអស់

*តារាង ៣. លទ្ធផលវិស័យឧស្សាហកម្មក្នុងឆ្នាំ២០០៥-២០០៦ (គិតជាភាគរយ)*

| | អត្រាកំនើនពិត | | ចំនែក ក្នុង ផសស | | ការរួមចំនែក ក្នុងកំនើន ផសស | |
|---|---|---|---|---|---|---|
| | 2005 | 2006 | 2005 | 2006 | 2005 | 2006 |
| ឧស្សាហកម្ម | **12.7** | **18.3** | **26.9** | **28.7** | **3.4** | **4.9** |
| រ៉ែ | 26.3 | 15.9 | 0.4 | 0.4 | 0.1 | 0.1 |
| ផលិតកម្ម | 9.7 | 17.4 | 19.6 | 20.8 | 2 | 3.4 |
| អគ្គិសនី ឧស្ម័ន និង ទឹក | 12.5 | 31.3 | 0.5 | 0.6 | 0.1 | 0.1 |
| សំណង់ | 22.1 | 20 | 6.4 | 6.9 | 1.3 | 1.3 |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិ ២០០៧*

នោះ ។ ការនាំចេញសំលៀកបំពាក់ពីកម្ពុជា ក្រោយពេលចប់ MFA មិនទាន់មានការប៉ះពាល់អ្វីពីប្រទេសចិន ដែលជាមហាយក្សខាងវាយនភ័ណ្ឌ ដូចការទស្សន៍ទាយនោះទេ ពីព្រោះសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប បានដាក់កំហិតបន្ថែមលើសំលៀកបំពាក់ចិន នៅខែឧសភា ២០០៥ ។ ប៉ុន្តែ វិធានការជួយគាំពារទាំងនេះនឹងផុតកំនត់ នៅឆ្នាំ២០០៨ ហើយវាអាចបង្កជាបញ្ហាដល់ប្រទេសកម្ពុជាយើង ។

អនុវិស័យសាងសង់បានលូតលាស់កាន់តែខ្លាំងក្នុងច្រើនឆ្នាំកន្លងមកនេះ ។ ការរីកដុះដាលសំនង់បណ្តាលមកពីកត្តាសំខាន់៧បី គឺៈ ស្ថិរភាពសេដ្ឋកិច្ច ដំណើរការសេដ្ឋកិច្ចរឹងមាំ និងជំនួយជាបន្តពីសហគមន៍អន្តរជាតិសំរាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ។ ការសាងសង់គឺមាន ១/៣ ជាសំណង់សាធារណៈ ដូចជាហេដ្ឋារចនាសម្ព័ន្ធជាដើម និង ២/៣ ជាសំណង់ឯកជន ដូចជា ការសាងសង់និងពង្រីករោងចក្រ សណ្ឋាគារ និងផ្ទះ ជាដើម ។ ប៉ុន្តែ មានការបារម្ភពីការវិនិយោគច្រើនលើសលប់លើសំនង់ផ្ទះនៅរាជធានីភ្នំពេញ ដែលមានការសាងសង់ដល់ ៨.០០០ ទៅ ១០.០០០ផ្ទះល្វែងក្នុងមួយឆ្នាំៗ ។

អនុវិស័យផ្សេងៗទៀតរួមមាន រ៉ែ អគ្គិសនី ឧស្ម័ន និងទឹក មានកំនើនវិជ្ជមានធៀបនឹងឆ្នាំមុន ប៉ុន្តែ ការរួមចំណែកដល់ការរីកលូតលាស់វិស័យឧស្សាហកម្ម និងកំនើនជារួមនៃ ផសស នៅតែតិចតួចនៅឡើយ ។ ប៉ុន្តែខាងរ៉ែមានសក្តានុពលច្រើនណាស់ ។ ការស្រាវជ្រាវពីដី និងរ៉ែ បានបង្ហាញថាប្រទេសកម្ពុជាមានរ៉ែជាច្រើន ដូចជា បូកស៊ីត រ៉ែត្បូង ប្រេងកាត រ៉ែលោហៈ និងមិនមែនលោហៈ និងសំភារៈបានពីកន្លែងជីកយកថ្ម ។ ដូចគ្នាដែរ ការផ្គត់ផ្គង់អគ្គិសនីបានល្អប្រសើរឡើងនៅតាមទីក្រុង ប៉ុន្តែប្រជាពលរដ្ឋនៅតែជួបការផ្តាច់ចរន្តអគ្គិសនីផ្លាស់វេនគ្នាក្នុងរដូវក្តៅ នៅខែមេសា និងខែឧសភា ។ អគ្គិសនីមានតំលៃខ្ពស់បានប៉ះពាល់ដល់គ្រប់វិស័យផលិតកម្ម និងបង្កឧបសគ្គដល់វិនិយោគខាងឧស្សាហកម្ម និងកំលាំងប្រកួតប្រជែង ។

## វិស័យសេវាកម្ម

វិស័យសេវាកម្មបានរួមចំនែក ៣៨,២% នៃ ផសស និងផ្តល់ការងារអោយ ២៨,១% នៃកំលាំងពលកម្មសរុប ។ វិស័យនេះ កើនបាន ១០,៣% នៅឆ្នាំ២០០៦ ធៀបនឹងកំនើន ១២,៧% នៅឆ្នាំ២០០៥ (តារាង ៤) ។ គ្រប់អនុវិស័យបានចូលរួមដល់កំនើននេះ ប៉ុន្តែសំខាន់ជាងគេ គឺការរីកដុះដាលខាងជំនួញ សណ្ឋាគារនិងភោជនីយដ្ឋាន អចលនទ្រព្យ សេវាកម្មជំនួញ និងសេវាកម្មផ្សេងទៀត ។ ទេសចរណ៍ មានចំណងទាក់ទងខាងដើមខ្សែ និងខាងចុងខ្សែជាមួយនឹងវិស័យដទៃៗទៀត ប៉ុន្តែថ្វីបើមានកំនើនយ៉ាងខ្លាំងក្នុងវិស័យទេសចរណ៍ក៏ដោយ ក៏ផលិតផលកសិកម្មក្នុងស្រុកមិនបានយកទៅប្រើប្រាស់អោយបានទូលំទូលាយនៅតាមភោជនីយដ្ឋាននានាទេ ពីព្រោះការផ្គត់ផ្គង់មិនសូវទៀងទាត់ទេ ហើយគុណភាពក៏ប្រែប្រួលដែរ ។ ប្រទេសកម្ពុជាអាចពង្រឹងចំណងទាក់ទងរវាងវិស័យទេសចរណ៍ និងកសិកម្មបានដោយជំរុញអោយមានការផ្គត់ផ្គង់ក្នុងស្រុកយ៉ាងទៀងទាត់ នូវម្ហូបអាហារមានគុណភាពខ្ពស់ ។

អចលនទ្រព្យ និងសេវាកម្មជំនួញ មានកំនើនមាំទាំល្អ ប៉ុន្តែក្នុងនេះ ការរីកដុះដាលនៃផ្នែកអចលនទ្រព្យ បានចូលរួមចំណែកខ្លាំងក្លាជាងសេវាកម្មជំនួញ ។ សេវាកម្មដទៃៗទៀតបានរីកលូតលាស់គួរអោយចាប់អារម្មណ៍ណាស់ ជាអាទិ៍ សេវាកម្មឯកជនផ្តល់ការអប់រំនិងថែទាំសុខភាព សេវាកម្មលំហែកំសាន្ត សេវាកម្មសហគមន៍ និងសេវាកម្មកែសម្ផស្ស ។

គួរកត់ចំណាំថា តួលេខ ផសស ត្រូវកែតំរូវឡើងវិញនៅពេលមានការពង្រីកដែនគ្របដណ្តប់ និងទទួលបានទិន្នន័យអាចទុកចិត្តបានច្រើនថែមទៀត ។

## ការកែតំរូវតួលេខ ផសស

NIS បានបន្តកែលំអទិន្នន័យ ផសស រៀងរាល់ឆ្នាំ ដើម្បីបង្កើនភាពត្រឹមត្រូវនៃការប៉ាន់ស្មាន ។ ការកែតំរូវឡើងវិញត្រូវធ្វើជាចាំបាច់ ពីព្រោះនៅពេល NIS បានកើនកំរិតជំនាញក្នុងការប៉ាន់ស្មានពីចំនូលជាតិ NIS ក៏អាចពង្រីកសកម្មភាពសេដ្ឋកិច្ចដែលដាក់បញ្ចូលនៅក្នុងគណនី ហើយអាចទទួលបានទិន្នន័យកាន់តែប្រសើរឡើង ។ ការកែតំរូវដែលកំពុងអនុវត្ត ជាសញ្ញានៃកំនើនគុណភាពទិន្នន័យដែលនាំឱ្យមានកំនើនគុណភាពតួលេខប៉ាន់ស្មាននៃចំណូលជាតិ ។

ការផ្លាស់ប្តូរជាចំបងៗចុងក្រោយនេះ ឆ្លុះបញ្ចាំងជាសំខាន់ពីការពង្រីកទំហំគ្របដណ្តប់លើសកម្មភាពសេដ្ឋកិច្ច ទិន្នន័យកែតំរូវឡើងវិញបានពីបណ្តាស្ថាប័នរដ្ឋាភិបាល ក្រសួង និងអង្គការផ្សេងៗទៀត ហើយនិងការកែតំរូវវិធីចងក្រងទិន្នន័យ ។ ទំហំគ្របដណ្តប់បានពង្រីកបន្ថែមដើម្បីរួមបញ្ចូលទាំងផលិតផលដូងប្រេង ការប្រមាញ់និងសត្វព្រៃ និងការប្រមូលយកផលិតផលមិនមែនឈើ ។ កំណែលំអវិធីចងក្រងទិន្នន័យក៏មានផងដែរនូវ ការប៉ាន់ស្មានកាន់តែច្បាស់នូវផលិតផលមិនមែនលោហៈ និងផលិតផលលោហៈ ដើម្បីឱ្យកាន់តែស៊ីគ្នាជាមួយតំរូវការនៃឧស្សាហកម្មសាងសង់ ការផ្លាស់ប្តូរនៅក្នុងពាណិជ្ជកម្ម និងការដឹកជញ្ជូនចាប់ពីឆ្នាំ២០០០មក ព្រមទាំងការប្រែប្រួលនៃសន្ទស្សន៍បរិត្តផរណានៃថ្លៃ ដែលបានប្រើប្រាស់សំរាប់សកម្មភាពហិរញ្ញវត្ថុ និងរដ្ឋបាលសាធារណៈចាប់ពីឆ្នាំ២០០៣ ។ បន្ថែមទៅលើការកែតំរូវ ដែលផុសចេញពីការប្រែប្រួលទំហំគ្របដណ្តប់ និងវិធីចងក្រងទិន្នន័យ NIS ក៏បានដាក់បញ្ចូលនូវការផ្លាស់ប្តូរទាក់ទងទៅនឹងប្រភពទិន្នន័យ ដូចជា ទិន្នន័យកែតំរូវបានមកពីក្រសួងមួយចំនួន និងធនាគារជាតិនៃកម្ពុជា ។

*តារាង ៤. លទ្ធផលវិស័យសេវាកម្មៈ ឆ្នាំ២០០៥-២០០៦ (គិតជា%)*

| | អត្រាកំនើនពិត | | ចំនែកក្នុង ផសស | | ចំនែកក្នុង កំនើន ផសស | |
|---|---|---|---|---|---|---|
| | 2005 | 2006 | 2005 | 2006 | 2005 | 2006 |
| សេវាកម្ម | **12.7** | **10.3** | **38.4** | **38.2** | **4.9** | **3.9** |
| ជំនួញ | 8.5 | 7.1 | 8.7 | 8.4 | 0.8 | 0.6 |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 22.3 | 13.2 | 4.3 | 4.4 | 0.9 | 0.6 |
| ដឹកជញ្ជូន និងទូរគមនាគមន៍ | 13.3 | 4.3 | 6.8 | 6.4 | 0.9 | 0.3 |
| ហិរញ្ញវត្ថុ | 19.6 | 24 | 1.1 | 1.3 | 0.2 | 0.3 |
| រដ្ឋបាលសាធារណៈ | 5.9 | -1.2 | 1.5 | 1.4 | 0.1 | 0 |
| អចលនទ្រព្យ និង សេវាកម្មជំនួញ | 7.8 | 10.9 | 7.6 | 7.6 | 0.6 | 0.8 |
| សេវាកម្មផ្សេងៗទៀត | 17.4 | 16.7 | 8.3 | 8.7 | 1.4 | 1.4 |

*ប្រភពៈ វិទ្យាស្ថានជាតិស្ថិតិ ២០០៧*

*តារាង ៥. ការកែតំរូវតួលេខប៉ាន់ស្មាននៃផលិតកម្ម គិតតាមថ្លៃថេរ*

| | 1993 | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ការកែតំរូវ (ពាន់លានរៀល) | 26 | 20 | 13 | 20 | 18 | 25 | -46 | -7 | 46 | 101 | 96 | 117 | 143 |
| ទិន្នន័យកែតំរូវ | -23 | -31 | -39 | -33 | -36 | -31 | -103 | -64 | 34 | 64 | 30 | 23 | 12 |
| កំណែលំអ ទំហំគ្របដណ្តប់ | 49 | 51 | 52 | 54 | 55 | 56 | 57 | 57 | 0 | 0 | 0 | 0 | 0 |
| ការផ្លាស់ប្តូរ ក្នុងវិធីសាស្ត្រ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 12 | 37 | 67 | 94 | 131 |
| ការកែតំរូវ (%) | 0.3 | 0.2 | 0.1 | 0.2 | 0.2 | 0.2 | -0.4 | 0 | 0.3 | 0.6 | 0.6 | 0.6 | 0.7 |
| កំនើន ផសស ពិត | | | | | | | | | | | | | |
| ការផ្សព្វផ្សាយដំបូង ឆ្នាំ២០០៦ | | 9.1 | 6.4 | 5.4 | 5.6 | 5 | 11.9 | 8.8 | 8 | 6.5 | 8.5 | 10 | 13.5 |
| ការបោះផ្សាយពីមុន | | 9.2 | 6.5 | 5.3 | 5.7 | 5 | 12.6 | 8.4 | 7.7 | 6.2 | 8.6 | 10 | 13.4 |
| ការកែតំរូវ | | -0.1 | -0.1 | 0.1 | 0 | 0 | -0.6 | 0.3 | 0.4 | 0.3 | -0.1 | 0.1 | 0.1 |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិ ២០០៧*

ដូចមានចុះក្នុងតារាង ៥ ការកែតំរូវលើតួលេខប៉ាន់ស្មានពីមុននាំឱ្យមានការកែតំរូវតួលេខសរុបនៃ ផសស គិតតាមថ្លៃថេរ ដោយតំលើងជាមធ្យម ០,៣% ក្នុងនេះមានការកែតំរូវតំលើង ០,៣% សំរាប់ឆ្នាំ១៩៩៣ និង ០,៧% សំរាប់ឆ្នាំ២០០៥ ។ ការកែតំរូវទាំងនេះ ក៏នាំឱ្យមានការប្រែប្រួលបន្តិចបន្តួចនៅក្នុងអត្រាកំនើនចារិក និងអត្រាកំនើនពិត ។

ការផ្តល់មតិពីអ្នកប្រើប្រាស់ទិន្នន័យ ជាពិសេសអ្នកប្រើប្រាស់ការវិភាគតាមកំរងទិន្នន័យពីមួយឆ្នាំទៅមួយឆ្នាំ បានជំរុញអោយ NIS ផ្លាស់ប្តូរនយោបាយកែតំរូវរបស់ខ្លួននៅឆ្នាំ២០០៥ ដោយ NIS ស្នើឡើងថា នៅពេលអនាគត កំរងទិន្នន័យនឹងមានបញ្ចូលតែការកែតំរូវថយក្រោយត្រឹមឆ្នាំ២០០១ ប៉ុណ្ណោះ ។ ប៉ុន្តែតួលេខប៉ាន់ស្មានក្នុងគណនីជាតិបច្ចុប្បន្ន មានបញ្ចូលការប្រែប្រួលក្នុងទំហំគ្របដណ្តប់ និងការកែតំរូវដល់ឆ្នាំ១៩៩៣ (តារាង ៥) ។ កញ្ញា អ៊ូច ច័ន្ទតារានី និង លោក Keith Carpenter (២០០៦) បានតស៊ូមតិឱ្យមានការកែតំរូវពេញលេញនូវកំរងទិន្នន័យ ដើម្បីទទួលបានតួលេខល្អប្រសើរនៃគណនីជាតិ ។ វាជារឿងល្អណាស់ដែលបានឃើញថា មានការកែតំរូវពេញលេញសំរាប់តួលេខប៉ាន់ស្មានបច្ចុប្បន្ននេះ ។

ទោះបីគុណភាពតួលេខប៉ាន់ស្មានបានកើនឡើងក្តី ប៉ុន្តែនៅតែមានឧបសគ្គខ្លះដោយសារកង្វះព័ត៌មានតាមវិស័យ ដែលគ្រប់ជ្រុងជ្រោយ និងគួរឱ្យទុកចិត្តបាន ។ សំរាប់តួលេខនៃវិស័យសេវាកម្ម តាមមើលប្រហែលមិនទាន់មានតួលេខត្រឹមត្រូវល្អ នៃចំនួនមន្ត្រីរាជការទេ ។ ដូច្នេះការចូលរួមចំណែកនៃអនុវិស័យរដ្ឋបាលសាធារណៈនៅក្នុង ផសស មិនអាចវាស់វែងបានច្បាស់លាស់ទេ ហើយផលិតភាពរបស់វាក៏មិនអាចប៉ាន់ស្មានបានច្បាស់ដែរ ។ យោងតាមការប្រសើរឡើងនាពេលថ្មីៗនៅក្នុងរដ្ឋបាលស៊ីវិល និងគណនេយ្យសាធារណៈ ការប៉ាន់ស្មានឱ្យបានត្រឹមត្រូវ នូវចំនួនមន្ត្រីរាជការ ហាក់ដូចជាមិនលំបាកពេកទេ ។ ច្បាប់ស្ថិតិតំរូវអោយអ្នកឆ្លើយសំភាសន៍ផ្តល់ "ព័ត៌មានត្រឹមត្រូវ ពេញលេញ និងទាន់ពេល ដល់មន្ត្រីស្ថិតិមានការចាត់តាំង" ហើយនេះជាចំនុចតូចមួយដែលរដ្ឋាភិបាលអាចផ្តល់នូវគំរូល្អដល់សង្គមស៊ីវិលបាន ។

ជាទូទៅ គណនីជាតិសំរាប់ឆ្នាំ២០០៦ នៅតែត្រូវប៉ះពាល់ដោយកង្វះប្រភពទិន្នន័យសំរាប់វិស័យសំខាន់ៗមួយចំនួន ដូចជា ទិន្នន័យអង្កេតប្រចាំឆ្នាំលើគ្រឹះស្ថានរឹសហគ្រាស ទិន្នន័យអង្កេតប្រចាំឆ្នាំលើកំលាំងពលកម្ម ព្រមទាំងកង្វះខាតជាបន្តនូវ សន្ទស្សន៍ថ្លៃសំរាប់ផលិតករ ពាណិជ្ជកម្ម ការនាំចេញ និងការនាំចូល ។ ការចងក្រងសន្ទស្សន៍ថ្លៃសំរាប់ផលិតករម្នាក់ (PPI) បានចាប់ផ្តើមសាកល្បងធ្វើនៅឆ្នាំ២០០៥ តែត្រូវផ្អាកទៅវិញដោយសារខ្វះខាតធនធាន ហើយរឿងនេះ បានប៉ះពាល់មិនល្អទៅលើគុណភាពនៃការប៉ាន់ស្មាន ផសស ។

## សេចក្តីសន្និដ្ឋាន

សេដ្ឋកិច្ចកម្ពុជា ថ្វីបើមានមូលដ្ឋានតូចចង្អៀត ប៉ុន្តែបានបន្តកើនឡើងយ៉ាងមាំមួនក្នុងឆ្នាំ២០០៦ ហើយកត្តាជំរុញសំខាន់គឺ ការរីកលូតលាស់ក្នុងផលិតកម្មកាត់ដេរ និងការរីកចំរើនដ៏ខ្លាំងក្លានៃទេសចរណ៍ ។ ប៉ុន្តែ ចំណងផ្សារភ្ជាប់រវាងអនុវិស័យទាំងពីរ និងផ្នែកផ្សេងៗទៀតក្នុងសេដ្ឋកិច្ច នៅមិនទាន់រឹងមាំទេ ។ យោងតាមការផ្លាស់ប្តូរក្នុងគោលនយោបាយអន្តរជាតិដែលគ្រប់គ្រងពាណិជ្ជកម្មវាយនភ័ណ្ឌនិងសំលៀកបំពាក់ កិច្ចប្រឹងប្រែងបច្ចុប្បន្ន សំដៅបង្កើនផលិតភាព និងកំរិតប្រកួតប្រជែងនៃវិស័យកាត់ដេរ ក៏ដូចជាការធ្វើចំរុះកម្មទំនិញនាំចេញ គឺចាំបាច់បំផុតដើម្បីជំរុញកំនើនសេដ្ឋកិច្ចបន្ថែមទៀត ។

## កំណត់សំគាល់

១.ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (២០០៧)

២.អេង នេត្រា និង ភឹម រ៉ុនស៊ីណារិទ្ធ (២០០៧)

៣.ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា: ព័ត៌មានវិនិយោគ http://www.cambodiainvestment.gov.kh ។

## ឯកសារយោង

Council for the Development of Cambodia, Investment Information, http://www.cambodiainvestment.gov.kh/

Eng Netra & Phim Runsinarith (2007), "Cambodia: A Macro View from 2007 to the Medium Term—Key Indicators for Growth, Development and Shared Prosperity", *Cambodia Development Review,* Volume11, Issue 2 (Phnom Penh: Cambodia Development Resource Institute)

Ministry of Agriculture, Forestry and Fisheries (2007), "Annual Report on Agriculture, Forestry and Fisheries 2006-2007" (Phnom Penh)

National Institute of Statistics (2007), "National Accounts of Cambodia 1993-2006" (Phnom Penh)

Ouch Chandarany and Keith Carpenter (2006), "Solid Economic Growth and Improved Accounting Methodology: A Review of the Cambodian National Accounts Estimates for 2005", *Cambodia Development Review,* Volume 10, Issue 3 (Phnom Penh: Cambodia Development Resource Institute)